ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ២២ ហិកតា ក្នុងក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

## សម្រេច

**មាត្រា១.**_

កាត់ដីទំហំ ២២ ហិកតា(ម្ភៃពីរហិកតា) ស្ថិតនៅក្នុងភូមិផ្សារឆ្នាំង និងភូមិកោះក្របី សង្កាត់ផ្សារឆ្នាំង និងភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ចេញពីដីក្នុងតំបន់២ នៃបឹងទន្លេសាប និងសារាចរណែនាំ



ɣ

០២ សរណោន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាល និងធ្វើអនុបយោគដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូន ឧកញ៉ា ណាង សុធី សម្រាប់អភិវឌ្ឍន៍លំនៅឋាន ដែលមានតម្លៃសមរម្យ សម្រាប់លក់ជូនមន្ត្រីរាជការនិងប្រជាជនក្នុងខេត្តកំពង់ឆ្នាំង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចខាងក្រោម៖

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 464589.342 | 1355795.036 | 20 | 464159.092 | 1355551.931 |
| 2 | 464544.808 | 1356068.994 | 21 | 464183.062 | 1355503.141 |
| 3 | 464435.246 | 1356046.038 | 22 | 464179.457 | 1355500.094 |
| 4 | 464434.12 | 1356049.763 | 23 | 464185 | 1355493 |
| 5 | 464311.146 | 1356032.168 | 24 | 464207 | 1355506 |
| 6 | 464240.224 | 1356025.798 | 25 | 464233.071 | 1355471.513 |
| 7 | 464166.995 | 1356020.728 | 26 | 464341.424 | 1355566.708 |
| 8 | 464133.69 | 1356006.397 | 27 | 464346.095 | 1355562.28 |
| 9 | 464118.586 | 1355996.062 | 28 | 464367.967 | 1355571.874 |
| 10 | 464123.259 | 1355991.974 | 29 | 464335 | 1355626 |
| 11 | 464077.905 | 1355946.621 | 30 | 464381 | 1355660 |
| 12 | 464021 | 1355926.79 | 31 | 464385 | 1355655 |
| 13 | 464014 | 1355897.538 | 32 | 464397 | 1355667 |
| 14 | 464010.619 | 1355817.197 | 33 | 464405 | 1355679 |
| 15 | 464008.074 | 1355810.832 | 34 | 464464 | 1355698 |
| 16 | 464005.676 | 1355801.241 | 35 | 464482 | 1355706 |
| 17 | 464001.192 | 1355767.613 | 36 | 464504 | 1355723 |
| 18 | 463992.754 | 1355755.34 | 37 | 464523 | 1355737 |
| 19 | 464152.502 | 1355562.19 | 38 | 464536.886 | 1355750.225 |

**មាត្រា២._**

ត្រូវបានធ្វើប្រទានកម្មដីទំហំ ២២ហិកតា (ម្ភៃពីរហិកតា) ក្នុងភូមិផ្សារឆ្នាំង និងភូមិកោះក្របី សង្កាត់ផ្សារឆ្នាំង និងភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ខាងលើជាកម្មសិទ្ធិជូនឧកញ៉ាណាង សុធី។

**មាត្រា៣._**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំងត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ១ រោច ខែ បុស្ស ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ